# សំដែងពីព្រះនិព្វាន

LIBRARY
BUDDHIST INSTITUTE

ពុទ្ធសាសនបណ្ឌិត្យ
INSTITUT BOUDDHIQUE

២៥៦.
៣៣

## ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

២៩៦.៣៣

ព្រះធំញាណ

# គោលបំផុតរបស់ព្រះពុទ្ធសាសនា

ដោយ

ភិក្ខុ ណារទ ថេរៈ

លង្កាទ្វីប

LIBRARY
BUDDHIST INSTITUTE

( ប្រែដោយក្រមការ ជុំ–មៅ នៅពុទ្ធសាសនបណ្ឌិត្យ )

បោះពុម្ពលើកទី ២

INSTITUT BOUDDHIQUE

ក្រុងភ្នំពេញ

ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ

ព. ស. ២៥០៣

# NIBBANA

BUT SUPRÊME DU BOUDDHISME

PAR

LE VÉNÉRABLE

# NARADA BHIKKHU

DE LAṄKĀ (CEYLAN)

(VERSION CAMBODGIENNE)

PHNOM-PENH

EDITIONS DE L'INSTITUT BOUDDHIQUE

1960

ព្រះពុទ្ធសាសនាជាសាសនាឯក ព្រោះមានសេចក្ដីបរមសុខ គឺព្រះនិព្វានជាសម្បត្តិដ៏ឧត្តមបំផុត ហើយក្នុងសម័យសព្វថ្ងៃនេះមានមនុស្សដែលយល់តាម ដែលកាន់តាមលំអានពុទ្ធវិបនៈ បំនួន ៥០០.០០០.០០០ នាក់ ។

ប៉ុន្តែ បំពោះនឹងមនុស្សដែលធ្វេសប្រហែស ដែលព្រងើយកន្តើយ នោះកែវដ៏ប្រពៃនេះហាក់ដូចជាមិនមានតំម្លៃ ហើយមិនគួរនឹងស្វែងរកឡើយ តែបំពោះនឹងមនុស្សដែលមានប្រាជ្ញាញាណឆ្លៀវឆ្លាស ហើយដែលធុញទ្រាន់នឹងសេចក្ដីឈឺចាប់ (ទុក្ខ)វិញ នោះកែវដ៏ប្រពៃនេះឯង ទៅជាវត្ថុមួយប្រសើរបំផុតដែលគួរស្វែងរក ។

ទោះអ្នកឯណាបេះពោលអំពីរឿងអ្វីមួយ ដែលជាទីសំខាន់មានលក្ខណហាក់ដូចម្ដេចក្ដី ហើយទោះបីក្នុងសេចក្ដីដែលពោលនោះគេបេះជ្រើសរើសសេចក្ដីដែលខ្ពង់ខ្ពស់យ៉ាងណា ដើម្បីនឹងអធិប្បាយអំពីសេចក្ដីបរមសុខនៃព្រះនិព្វានក្ដី ក៏សេចក្ដីដែលពោលនោះមិនអាចនឹងត្រូវបំឡើយ ព្រោះបាតាមដោយពិតនោះមិនមានអ្នកឯណាអាចស្គាល់បាន ថាព្រះនិព្វាននោះជាអ្វីទេ គឺ

គ្រាន់តែបានមើលសេចក្ដីផ្សេងៗ ដែលពោលអំពីព្រះនិព្វាន ប៉ុណ្ណោះ ។

ព្រះនិព្វានដែលពិតប្រាកដនោះ ជាវត្ថុដែលអធិប្បាយមិនរួចដែលឥតឧបមាហើយដែលវិជ្ជាមនុស្សនឹងចាប់មិនបានព្រោះព្រះនិព្វាននេះជាឋានខ្ពស់លើគេទាំងអស់ ហើយដែលអាចនឹងយល់ច្បាស់ប្រាកដបាន បានតែដោយការយល់ស្ដែងរបស់ប្រាជ្ញាញាណ គឺជាសេចក្ដីពិតសម្រេចឥតសង្ស័យ ។ ប៉ុន្តែមិនមែនជាការត្រូវ ឬមិនមែនជាផ្លូវសេចក្ដីឡើយ ប្រសិនបើយើងមិនល្បងរិះគិតឲ្យជាក់លាក់អំពីព្រះនិព្វាននេះ ដរាបដល់ពេលដែលយើងបានដល់ឋានជាន់ខ្ពស់ ដែលអាចធ្វើឲ្យយើងឃើញនូវព្រះនិព្វាន។បើមិនដូច្នោះទេគេអាចនឹងបន្ទោសយើងបានដូចយ៉ាងមនុស្សជំទង់ម្នាក់ដែលមិនស្គាល់នូវត្រៃវិជ្ជា ត្រូវបន្ទោសដូច្នេះ នែសំឡាញ់ចុះហេតុដូចម្ដេចបានជាឯងធ្វើដំណើរ ដើម្បីឡើងទៅកាន់វត្ថុដែលឯងស្មានថាជាផ្ទះ ហើយដែលឯងមិនឃើញមិនយល់សោះនោះ ឯផ្លូវដែលយ៉ាងជាក់ស្បាត់ ដើម្បីនឹងរិះគិតអំពីព្រះនិព្វាននោះ គឺត្រូវពិចារណាតាមលំអានព្រះពុទ្ធ-

វិបុន: ៗ ក្រៅអំពីព្រះពុទ្ធសាសនា គេអាចនឹងបង្ហាត់ឬបង្វឹកនូវអំណាចស្មារតីរបស់គេបានអំពីដែលមានមោក្ខធម៌ គឺព្រះនិព្វាននេះឯង ។

ដោយហេតុនេះហើយ បានជាព្រះសម្មាសម្ពុទ្ធជាម្ចាស់កាលដែលព្រះអង្គអន្ទោលក្នុងវដ្តសង្សារនូវឡើយនោះទ្រង់បានពិចារណាឃើញសេចក្តីយ៉ាងធ្ងន់ធ្ងរនូវវេលាដែលកំពុងបំពេញបារមី។

តែកាលណាទុក្ខមានហើយ រីសេចក្តីសុខក៏អាចមានបាន។

តែកាលណាមានជាតិហើយ អ្វីដែលមិនមែនជាជាតិក៏គង់នឹងរកឃើញបាន ។

តែកាលណាបំពាយក្តៅមានហើយ រីបំពាយត្រជាក់ក៏គង់មានបាន ។

តែកាលណាភ្លើង ៣ មានហើយ រីព្រះនិព្វានក៏អាចនឹងរកឃើញបាន ។

តែកាលណាសេចក្តីអាក្រក់មានហើយ រីសេចក្តីល្អក៏គង់មានមិនខាន ។

តែកាលណាកំណើតមានហើយ អ្វីដែលមិនមែនជាកំណើតក៏អាចរកឃើញបាន ។

ផ្ទុយឈ្មោះឃើញថា នូវវេលាដែលបាននូវរំពឹងដោយយោបល់អំពីសភាពជាក់ស្តែងនឹងបដិសេធន៍របស់ជាតិ នោះព្រះអនាគតពុទ្ធ ក៏បានដល់នូវសេចក្តីយល់ឃើញយ៉ាងជាប់ខាត ថាត្រូវតែមានព្រះនិព្វានដែលគ្មានឈឺគ្មានស្លាប់ ហើយដែលជាសភាពផ្ទុយគ្នា នឹងសំសារដែលជាសភាពប្រកបដោយទុក្ខ ហើយប្រែប្រួលជានិច្ច ឬបើនឹងពោលដោយសព្ទផ្សេងទៀតវិញនោះ គឺថាត្រូវតែមានជាតិយ៉ាងជាប់ខាត ១ ដែលជំទាស់ផ្ទុយគ្នានឹងជាតិដែលប្រកបដោយអភេទផ្សេងៗ ប៉ុន្តែទោះយោបីពិចារណាតាមផ្លូវសេចក្តី ឬតាមលំអានវិទ្យាសាស្ត្រក្តី ក៏មិនអាចនឹងយល់បាននូវខ្លឹមសារនៃព្រះនិព្វាន ព្រោះព្រះនិព្វាននេះជា អតក្កាវចរ ហើយមិនអាចនឹងឈោងចាប់បាន ឬយល់បាននូវខ្លឹមសារដោយអំណាចវិធីក្បួនខ្នាតឡើយ ។

នែសំឡាញ់ សារីបុត្ត ខ្ញុំឮតែគេថា និព្វាន និព្វាន តើអ្វីដែលជានិព្វាននោះ ។

ប្រស្នានេះឯង ដែលព្រាហ្មណ៍ម្នាក់បានចោទ កាលពី ២.៥០០ ឆ្នាំកន្លងមកហើយ អំណើះ ៥០០ ឆ្នាំតពីនោះមក ព្រះចៅមិលិន្ទ បានយកប្រស្នាដដែលនេះមកចោទម្តងទៀតនៅ

ស្រុកសាគល ។ ដោយឃើញថាប្រស្នានេះហាក់ដូចជាមិនទាន់ច្បាស់នៅឡើយ នោះទើបយើងអាចហ៊ានមកផ្ដើមពោលម្ដងទៀត ក្នុងទំព័រដែលមានតទៅនេះ ។

ពាក្យបាលីថា "និព្វាន" ដែលត្រូវសំគាល់ថាចេញមកពីពាក្យសំស្ក្រឹត "និរ្វាណ" ហើយដែលបំពាក់គំនិតស្របចូលទៅក្នុងគំនិតព្រាហ្មណ៍ផង នោះកាត់ចេញទៅជាពីរបទគឺ "និ" នឹង "វាណ" និ ជាសួនរបស់បដិសេធន៍ ហើយ វាណ ដែលត្រូវប្រែថាតណ្ហាញ្ញុប្រាថ្នា មានសភាពក្នុងទីនេះជាខ្សែ ដើម្បីចងជាតិរបស់យើងភ្ជាប់ពីមួយ ទៅ មួយ ។

វិធមិដែលជួយយើងឲ្យរបួតពីសេចក្ដីប្រាថ្នា ឬដែលជួយដោះយើងឲ្យរបួតពីបំណងនោះមានឈ្មោះថា និព្វាន ។

ព្រះអនុរុទ្ធបេរ លោកបានពោលពន្យល់ក្នុងព្រះអភិធម្មបំប្រួញថាដូច្នេះ បានជាហៅថានិព្វាន ព្រោះជាសេចក្ដីរដោះ និចេញពីសេចក្ដីប្រាថ្នាគឺវាណ តែជាប់បំណងរបស់សេចក្ដីប្រាថ្នាជិវាបណា ក៏តែងតែនឹងសន្សំ កម្មជាកំលាំងថ្មីទៀតដិវាបនោះអំពើដែលសន្សំនោះហើយ នាំយើងឲ្យវិលវល់ក្នុងសេចក្ដីកើតស្លាប់ត ៗ ទៅឥតមានស្រាក ។

លុះតែកាលណា បានទំលាយកាប់បំបាក់នូវតណ្ហា គឺសេចក្ដីប្រាថ្នាចេញហើយ ទើបកំលាំងកម្មនោះនឹងប្រព្រឹត្តទៅៗទៀតមិនបាន ហើយក្នុងស្ថាននេះគេអាចនឹងចាប់យកបាននូវព្រះនិព្វាន ហើយគេបភៀសឡផុតអំពីវដ្ដសំសារ ។

ពាក្យនិព្វាននេះគេអាចនឹងពន្យល់ថារំលត់បានដែរ គឺរំលត់ភ្លើងប្រាថ្នា (លោភ) រំលត់ភ្លើងកំហឹង (ទោស) និងរំលត់ភ្លើងវង្វេង(មោហ)ព្រះសព្វញ្ញុពុទ្ធជាម្ចាស់ទ្រង់សម្ដែងថា លោកទាំងមូលពាសពេញទៅដោយអណ្ដាតភ្លើង តើភ្លើងអ្វីដែលដុតនេះ គឺភ្លើងរបស់ លោភ ទោស មោហ និងភ្លើងរបស់ជាតិ ជរា មរណ ព្យាធិ សោក ទុក្ខទោមនស្ស នេះឯង (សំយុត្តនិកាយ សៀវភៅទី៤ ទំព័រ២៥១ ក្នុងពួកសៀវភៅបាលីតេកស្សសៀទី)ៗ

ពាក្យថានិព្វាន មានន័យម្យ៉ាងទៀតថា រំលត់នូវភ្លើងនេះ ព្រោះថាកាលដែលព្រះសារីបុត្ត បានឆ្លើយតបសេចក្ដីចោទន៍របស់ ជម្ពុខាទក ក្នុងគម្ពីរសំយុត្តនិកាយ នោះមានសេចក្ដីថា ជួបេ្ពះ និព្វានគឺជាសេចក្ដីរំលត់លោភ ទោស និងមោហ ។

ប៉ុន្តែបើទោះណាជាជួបេ្ពះក្ដី ក៏កុំត្រូវយល់ថា និព្វាននេះ គ្មានអ្វីក្រៅអំពីរំលត់អកុសលមូលខាងលើនេះឡើយ ។

គម្ពីរវិសុទ្ធិមគ្គសំដែងថា

.១៨មគ្គមេរ៉ៈ ន និព្វានំតិ វត្តព្វំ - កុំគប្បីពោលថា និព្វាន ជាសេចក្តីរំលត់តែម្យ៉ាងឡើយ ។

ព្រះសារីបុត្តថេរ កាលដែលលោកសម្តែងនោះ គឺលោក គ្រាន់តែកត់សំគាល់អំពីផ្លូវ ឬឧបាយទៅកាន់ព្រះនិព្វានប៉ុណ្ណោះ លុះតក្រោយមកទៀត លោកបានសម្តែងវិសជ្ជនាដដែលទៀត នូវវេលាដែលមានប្រស្នាចោទលោកអំពីសភាពនៃព្រះអរហន្ត ។

ដែលយល់ថាព្រះនិព្វាននោះជាសូន្យទទេតែម្យ៉ាង ដោយ ហេតុថាវិជ្ជាសម្រាប់លោកមិនអាចយល់បាន នោះក៏មិនត្រូវតាម ផ្លូវសេចក្តីឡើយ តែជឿដូច្នេះទៅ ហាក់ដូចមនុស្សខ្វាក់ជឿថា ពន្លឺមិនមាន ព្រោះមនុស្សខ្វាក់មិនដែលបានប្រទះឃើញដូច្នោះ មានឧបមាដូចម្តេចមិញ ថាមានឧបមេយ្យដូចជាសេចក្តីដែល មានក្នុងរឿងត្រីនឹងអណ្តើកជាមិត្រនឹងគ្នា បានពិភាក្សាជជែក គ្នាហើយក៏បុះជឿជាសម្រេចថា ផែនដីមិនមានឡើយ ។

ប្រសិនបើនិព្វានជាសូន្យទទេនោះនឹងប្រឡំគ្នានឹងអាកាស មិនខាន ក្នុងគម្ពីរអង្គុត្តរនិកាយ ព្រះសាស្តាចារ្យទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយមានធម៌ ២ ដែលទៀងជានិច្ចដែលមាននៅ

ជានិច្ចជានិរន្តរ៍ ដែលឥតប្រែប្រួល ដែលឥតផ្លាស់ប្ដូរ ធម៌នេះឯងគឺអាកាស១ នឹងនិព្វាន១ អាកាសមាននៅជានិច្ច ព្រោះអាកាសនេះមិនមែនជាអ្វីដែលមានរូប ហើយសេចក្ដីដែលប្លែកគ្នាអំពីអាកាសនឹងនិព្វាននោះ គឺថាមួយគ្មាន មួយមាន ។

ការដែលព្រះអរហន្តលោកទុកព្រះនិព្វានជាវត្ថុធម៌១នោះ បញ្ជាក់ដោយជាប់ខាតថា និព្វានមិនមែនជាសភាពសូន្យទទេឡើយ ប្រសិនបើនិព្វានជាសូន្យទទេវិញ នោះតើនឹងមានផលប្រយោជន៍អ្វីដល់ព្រះសម្មាសម្ពុទ្ធ ដែលទ្រង់ទំឡន់យផ្សេងៗជាច្រើនអំពីព្រះនិព្វាននេះ ដូចយ៉ាងន័យដែលថាទឹកអម្រឹតសេចក្ដីក្សេមឥតផុត (ខេម) សេចក្ដីដែលមិនស្លាប់ (អមត) សេចក្ដីដែលរួចខ្លួនជាស្រឡះ(មុត្តិ)សេចក្ដីក្សាន្ត(សន្តិ)ហើយនឹងន័យឯទៀតជាច្រើនទៅទៀត ។

រីព្រះនិព្វានរបស់ព្រះសព្វញ្ញុតញ្ញុទ្ធជាម្ចាស់នោះ មិនមែនជាសភាពទទេឥតអ្វីសោះ មិនមែនជាសភាពសូន្យផុត ។

-| សោបាទិសេស នឹងអនុបាទិសេសធាតុ ក្នុងគម្ពីរនានាបានប្រទះឃើញជាញឹកញយ ដែលពោលអំពីព្រះនិព្វានថា ជា

សោបាទិសេសនឹងអនុបាទិសេស តាមដោយពិតនោះមិនមែនជាមានព្រះនិព្វាន២យ៉ាងទេ គឺមានតែម្យ៉ាងប៉ុណ្ណោះ ប៉ុន្តែព្រះនិព្វាននេះទទួលនាមបញ្ញត្តិតាមលំអាន ដែលបានច្បាស់ជាមុននឹងជាក្រោយសេចក្ដីស្លាប់ ។

សោបាទិសេស នៅមានសេសសល់ នៅមានឋាន ១ សម្រាប់ព្រះអរហន្តដែលនឹងចាប់យកនូវព្រះនិព្វាន រីឯរូបដែលសល់នៅនោះមានសណ្ឋានដូចជា គ្រាប់ឈើ ដូច្នោះ ។ ក្នុងសណ្ឋាននេះយើងកុំត្រូវភ្លេចថាព្រះអរហន្តទាំងឡាយលោកមិនបានសោយសុខរបស់ព្រះនិព្វានជារាបតរៀងទៅ ក្នុង១ ជាតិរបស់លោកនោះឡើយ ។

អនុបាទិសេស ឥតមានសេសសល់ សម្រាប់ព្រះនិព្វានដែលពិត ហើយដែលជាឋាននៃព្រះអរហន្តនឹងព្រះពុទ្ធនូវវេលាដែលទំលាយរូបទៅ ។ សេចក្ដីពិចារណាឬត្រិះរិះដោយមិនបត់អំពីព្រះត្រៃលក្ខណញ្ញាណ ដែលព្រះសម្មាសម្ពុទ្ធសំដែងអំពីព្រះនិព្វាននោះ អាចនឹងជួយគំនិតយើងឲ្យបានយល់ខ្លះ អំពីបែបសណ្ឋាននៃព្រះនិព្វាន នៅវេលាដែលទ្រង់ប្រារព្ធដល់សេចក្ដីប្លែកគ្នាអំពីនិព្វាននឹងសំសារនោះព្រះសាស្ដាបារម្ភទ្រង់សំដែងថា

ព្រះនិព្វាននោះទៀងជានិច្ច (ធុវ) ជាស្ថានល្អគួរស្វែងរក (សុភ) ហើយជាទីស្រួល (សុខ) ។

តាមលំអានព្រះពុទ្ធសាសនា វត្ថុអ្វីដែលមានក្នុងលោកនេះក្តី មិនមានក្នុងលោកនេះក្តី បំណែកចែកចេញជា ២ ពួកទាំងអស់ គឺចែកចេញជារបស់ដែលយល់បានដោយហេតុ (សំខត) នឹងជារបស់ដែលយល់មិនបានដោយហេតុ (អសំខត) ។

របស់ណាដែលជាសំខតគឺរបស់ដែលមានក្នុងលោកនេះទាំងប៉ុន្មានតែងតែផ្លាស់ប្តូរប្រែប្រួលឥតមានស្រាក ហើយមិនដែលនៅនឹងថិដែលពីពេល១ ទៅពេល១ ដែលជាលំជាប់គ្នាឡើយ។

ឯសេចក្តីពិតនេះ ដែលសម្តេចព្រះអនាវរញ្ញាណសាស្តាចារ្យ ជាអ្នកប្រាជ្ញធំបំផុតក្នុងបូព៌ាប្រទេស បានសំដែងទុកតាំងពី ២.៥០០ ឆ្នាំកន្លងមកហើយ ទើបតែនឹងបានយល់ដល់អ្នកប្រាជ្ញខាងបច្ឆិមប្រទេស ដោយហេតុថាតាំងពីដើមរៀងមកទល់នឹងឆ្នាំ ១៨៥៩ គឺថាមុន៧១ឆ្នាំដែលកន្លងមក គេបានប្រកាន់ជឿថាមាន ធាតុ ១ ដែលជាបរមាណូឥតប្រែប្រួល ឥតវែកបែកបាន ហើយដែលគេជឿថា ជាវត្ថុដែលពិតប្រាកដ ត្រូវតែជឿខានមិនបាន ។

ប៉ុន្តែវិធីដែលជឿនេះ មានអ្នកប្រាជ្ញដែលវៀវឆ្លាសជាងគេ បានបដិសេធបោល ថាជារបស់មិនពិតវិញ ហើយក្នុងវេលានេះគេទុកដាក់បរមាណូនោះថា ធម្មជាតិដែលកើតឡើងជាកំលាំងស្រួបតែងកម្រើកជានិច្ច ហើយតាំងលែបឹ្លងនូវកិច្ចការ និងការប្រែធាតុដែលគេមិនទុកថាជារបស់មិនវិនាសឡើយបំណែកខាងផ្លូវវិញ្ញាណវិញអ្នកស្រុកខាងបច្ចិមប្រទេស នៅកំពុងបម្រះនៅក្នុងទីងងឹតនៅឡើយ ប៉ុន្តែជាភព្វធំណាស់ ដែលមានអ្នកប្រាជ្ញបារាំងសេសម្នាក់ឈ្មោះ បែគ៌សុង និងអ្នកប្រាជ្ញអង្គ្លេសម្នាក់ឈ្មោះ វិល្លិអាំសាម បានរកឃើញថាវិញ្ញាណនោះក៏ជាសភាពដែលផ្លាស់ប្តូរជានិច្ចដែរក្នុងវេលា២វិនាទីមិនដែលវិញ្ញាណដដែលនោះគង់នៅឡើយ គឺផ្លាស់ជាថ្មីទាំងអស់ អ្វីៗដែលមានភាពសណ្ឋានជាវិញ្ញាណ នោះសឹងជាប់ជំពាក់ ១ ខណៈមកក្នុងជីវិត ប៉ុន្តែមិនមែនជាសភាពដែលមិនលុះក្នុងធម៌ប្រែប្រួលនោះឡើយគឺជាសភាពដែលតែងប្រែប្រួលឥតមានអាក់ រីជីវិតដែលប្រកបដោយតាមនឹងរូបនោះជារលកដែលប្រព្រឹត្តទៅជានិច្ច ជាអាការកម្រើកដែលឥតមានឈប់ ។

ដើម្បីនឹងពន្យល់ន្វូវធម៌ប្រែប្រួលដែលមានទូទៅនេះ មិនបាច់នឹងទៅរកឧទាហរណ៍ ឬសេចក្ដីឧបមាឯណាមកសំដែងឲ្យច្រើននោះឡើយ យកតែរឿងរ៉ាវក្នុងសម័យអតីតកាលអំពីប្រទេសនានាមកពោល ដូចយ៉ាងសេចក្ដីវិនាសរបស់នគរណា ៗ ដែលជានគរមានឫទ្ធានុភាពខ្លាំង ហើយនឹងអំពីសេចក្ដីប្រែប្រួលផ្លាស់ប្ដូរយ៉ាងរហ័សឆាប់របស់មនុស្សលោកយើង ក្នុងមួយជាតិ ៗ ក៏មនុស្សដែលមានគំនិតអាចនឹងយល់ទៅបាន ថាសេចក្ដីកើតនឹងរលត់ ទៅនឹងមក តែងប្រព្រឹត្តទៅមិនផុត ។

អ្វីដែលកើតឡើងអំពីហេតុ មានធម្មតាត្រូវតែរលត់ទៅវិញដូច្នេះឃើញថាជាអសុភទាំងអស់ អ្វីដែលជាបណ្ដោះអាសន្ននឹងជាអសុភនោះ មិនអាចទៅជាសុខបានឡើយ ។

ដែលយើងហៅថាសុខនឹងសោមនស្ស នោះគឺជាផលនៃសេចក្ដីប្រាថ្នានោះឯង របស់ណាដែលយើងចង់បានហើយបានមកដូចសេចក្ដីប្រាថ្នា តែនមិយូរប៉ុន្មានក៏មិនពេញចិត្តនឹងរបស់នោះទៅវិញព្រោះសេចក្ដីប្រាថ្នាមិនមានផ្អែតមិនមានស្កប់ឡើយក្រោយមកយើងប្រាថ្នាទ្រព្យសម្បត្តិទៀត ហើយក៏បានដូចបំណង ប៉ុន្តែយូរបន្តិចទៅ ក៏កើតសេចក្ដីមិនពេញចិត្តនឹងភោគ-

សម្បូរទៅទៀត តាំងប្រាថ្នាយសសក្តិជាថ្មី ហើយក៏បានយស សក្តិនោះតាមបំណុបចិត្ត ។ លុះបានយសសក្តិហើយ ក៏ឃើញ ថាធ្វឹបជាឯកឯងពេកណាស់ ដោយគ្មានរិទ្ធិអំណាច រីចិត្តរបស់ យើងក៏មិនព្រមសុខ ខ្លួនយើងក៏តាំងប្រាថ្នាបង់ឲ្យមានឫទ្ធានុ- ភាពទៀត ហើយសេចក្តីបំណងនេះក៏សម្រេចឡើង ប៉ុន្តែខ្លួន យើងនឹងទៅជាវង់សម្រាប់បាញ់របស់មនុស្សដែលឥច្ឆាឈ្នានីះ ក្នុងលោកនេះ តើសេចក្តីសោមនស្សរីករាយយ៉ាងណា ដែលមិន បាត់រស់ទៅវិញក្នុង ១ កាល១ គ្រានោះ សេចក្តីសុខយ៉ាងណា ដែលយើងអាចស្គាល់បានថាជាសុខអង្វែងឥតប្រែប្រួល ហើយ ដែលមិនធុញទ្រាន់នោះ ។ ក្នុងលោកនេះ តើសេចក្តីត្រេក ត្រអាល ឬសេចក្តីសាទររីករាយយ៉ាងណា ដែលយើងអាចនឹង ទ្រទ្រង់បានអស់កាលដ៏យូរ សេចក្តីសុខក្នុងមនុស្សលោកក្តី ឬ សេចក្តីសុខក្នុងទេវលោកក្តី សុទ្ធតែជាតម្រាយទៅកាន់ទុក្ខទាំង អស់ ទុក្ខនេះជាសំខាន់របស់ជាតិ មិនអាចនឹងជៀសវាងផុត ឡើយ ។

អ្នកប្រាជ្ញបរមត្ថ ជាតិអាល្លឺម៉ង់ឈ្មោះ ឆូប៉េនហូវែរ បាន ពោលថា រីទុក្ខនេះបើមិនអាចនឹងសំដែងអាការឲ្យឃើញជារូប

វាងជាក់ច្បាស់ ក៏គង់បេញមកជាអាការព្រលាំ ដូចយ៉ាងសេចក្ដីអផ្សុកនឹងស្រងេះស្រងោចនោះមិនខាន ។

ប៉ុន្តែ និព្វាន ជាវត្ថុដែលមិនមែនតាក់តែងឡើង ដែលមិនមែនកើតឡើងដោយហេតុ និព្វាននេះជាសភាពប្រាសផ្ទុយគ្នានឹងសំសារ និព្វានទៀងជានិច្ច(ធុវ)ជាវត្ថុល្អគួរប្រាថ្នាយក(សុភ) គួរសប្បាយ(សុខ) គឺជាសេចក្ដីបរមសុខ ជានគរសុខ.ជាសេចក្ដីសុខដែលមិនបេះរេចរិលសោះ.ជាសេចក្ដីដែលមិនជិនណាយសោះ ដែលមិនបេះរលោះសោះ.ហើយដែលមិនអណ្ដែតរសាត់រផ្សេងផ្សងទៅទីណា គឺជាសេចក្ដីសុខដែលប្រាកដឡើងដោយផលនៃសេចក្ដីរលត់អកុសលមូល (វូបសម) ហើយដែលជាសភាពប្លែកគ្នាហោយដាច់ខាតអំពីសេចក្ដីសុខក្នុងលោកនេះ ព្រោះសេចក្ដីសុខក្នុងលោកនេះកើតឡើងដោយអំណាចសេចក្ដីប្រាថ្នាប៉ុនប៉ង (វេទយិត) ។ មកដល់ត្រង់នេះឃើញជាភ្លឺសេចក្ដីទាំងអស់ ប៉ុន្តែប្រស្នាអំពីព្រះនិព្វាននោះតើនៅត្រង់ណា ។

ក្នុងមិលិន្ទបញ្ហា ព្រះនាគសេនថេរបានដោះប្រស្នាអំពីព្រះនិព្វានដោយឧទាហរណ៍ដូច្នេះ ឯទីកន្លែងរបស់ព្រះនិព្វាននោះមិនមែនកន្លែងដែលមានមុខទៅខាងកើត.ខាងត្បូង. ខាងលិច.

ខាងជើង.ខាងលើ:ខាងក្រោមឬខាងឆាយឡើយ ប៉ុន្តែបើទោះជាយ៉ាងណាក៏ព្រះនិព្វានមានដោយពិត ហើយកុលបុត្រណាដែលសំដៅយកគោលនោះ ត្រូវឲ្យមានសីលជាអាទិ ហើយត្រូវឲ្យមានសេចក្ដីប្រយ័ត្នយ៉ាងម៉ត់ចត់ ទើបនឹងបាប់យកនូវព្រះនិព្វានបាន ទោះបីកុលបុត្រនោះមានទីលំនៅៗ ស្រុកស្រែក្ដី ស្រុកបិនក្ដី ស្រុកអាឡឹកសង់ដ្រឹក្ដី ឬស្រុកកោសលក្ដី ដើម្បីនឹងអធិប្បាយពន្យល់សេចក្ដីព្រះនាគសេនថេរលោកបន្ថែមថា

ឧបមាដូចជាភ្លើងកាលដើមគ្មានក្នុងកន្លែងណាមួយទេតែនឹងអាចប្រាកដមានឡើងបានក្នុងកន្លែងនោះនៅវេលាដែលប្រកបដោយជាតុផ្សេងៗ ដែលគួរឲ្យកើតបានម៉ាន់ប្រការយ៉ាងណាវិព្រះនិព្វានក៏មានប្រការយ៉ាងនោះដែរ គឺថាកាលដើមព្រះនិព្វាននោះគ្មានក្នុងទីណាមួយទេ ប៉ុន្តែព្រះនិព្វាននេះនឹងរកបាននៅវេលាដែលកិច្ចការផ្សេង ៗ បានបំពេញជាស្រេចហើយ ហើយដើម្បីនឹងអធិប្បាយអំពីព្រះនិព្វានតាមសេចក្ដីពិត ដែលបេញអំពីពុទ្ធវចនៈនោះត្រូវពោលដូច្នេះ ព្រះនិព្វានមិនមែននៅត្រង់កន្លែងណាទេ ប៉ុន្តែស្រេចហើយតែគ្រោងកាយរបស់សត្វ គឺបព្រះនិព្វានមិនមែនជាបែមហានស្នេហ៍របស់ព្រាហ្មណ៍ ដែលមា

ឥន្ទ្រិយយ៉ាងវិសេសមួយនោះទេ គឺជាធម៌មួយ ជាឋានមួយយ៉ាងងាយ ប៉ុន្តែមិនជ្រាបមិនប៉ះពាល់ដល់ប្រាជ្ញាធម្មតា ។

អ្វីដែលចាប់យកនិព្វាន ពាក្យនេះជាប្រស្នា១ផ្សេងដែលគួរឲ្យពិនិត្យប្រុងប្រយ័ត្នជ្រៀងផ្ទាត់ឲ្យម៉ត់ចត់ ប្រស្នានេះត្រូវតែទុកដោយបំណែកមួយអន្លើជារបស់ក្រៅផ្លូវសិន ព្រោះថាព្រះពុទ្ធសាសនាមិនទទួលថាមានធាតុទៀង នឹងព្រលឹងមិនស្លាប់ឡើយ ដែលយើងព្រមព្រៀងគ្នាហៅថា អត្តភាព ហើយអត្តភាពនោះគេតែងហៅថាជាសម្លៀកបំពាក់របស់វិញ្ញាណ បើពោលតាមភិក្ខុនីវជិរ ថាជាគំនរធម្មតានៃធាតុផ្សេងដែលផ្គុំគ្នា ។

ដូចជាដែលយើងហៅថា រថ នោះគឺហៅបានតែកាលណាគ្រឿងផ្សេង ៗ ប្រជុំគ្នាឡើង នោះមានឧបមាយ៉ាងណា ឬងខ្លួនមនុស្សវិញក៏ដូចគ្នា គឺដែលហៅថា "អត្តភាព" បាននោះ បានតែកាលណាមានធាតុផ្សេង ៗ ជួបជុំគ្នាទាំងអស់ មានឧបមេយ្យដូច្នោះឯង ។

តាមលំអានព្រះពុទ្ធសាសនាថាគ្មាន "អត្តភាព" ដោយពិតប្រាកដនោះទេ គួរអត្តភាពជាទីប្រជុំនៃនាមធម៌នឹងរូបធម៌ ឯនាមធម៌នឹងរូបធម៌នោះសុទ្ធតែនូវក្នុងសណ្ឋានប្រែប្រួលជានិច្ច ។

រូបធម៌ឬប៉ែកដែលប្រកបតាក់តែងឡើង នោះជាសភាពដែលទទួលសម្មុស្សនៃអត្តភាព តួអត្តភាពនេះហើយដែលគេហៅថាជាគ្រឿងសម្លៀកបំពាក់របស់វិញ្ញាណ ក៏ឯរូបធម៌នោះមិនគឺអ្វី គឺជាកម្លាំងពលំនឹងជាតុឬវិញ្ញាណ ដែលជាទីនៅរបស់បរមាណូនោះ ក៏ប្រកបដោយខណៈចិត្តដែលកើតត ៗ គ្នាដែរ ជីវិតិន្ទ្រិយជាខ្សែទឹកដែលជាប់មិនបេះដាច់មិនមែនជាព្រលឹងដែលមិនប្រែប្រួលនៅក្នុងអត្តភាពមនុស្សឡើយ ព្រះពុទ្ធសាសនាទទួលជឿថា មានជីវិតិន្ទ្រិយដែលតែងប្រែប្រួលឥតអាក់ ប៉ុន្តែមិនទទួលជឿឬមិនស្គាល់នូវអហំការ សម្រាប់បុគ្គលឡើយ ដោយគ្មានឥន្ទ្រិយដែលទៀងជានិច្ចនឹងគ្មានអហំការ សម្រាប់បុគ្គលដូចនេះនោះជាឥតប្រយោជន៍នឹងពោលថាព្រះនិព្វាននោះគ្មាន "ឥន្ទ្រិយ" ឡើយ សេចក្តីដែលនឹងពោលទៅនេះអាចនឹងយល់បាន :

"សេចក្តីលំបាកមាន តែមិនមែនមនុស្សលំបាក
អ្នកដែលប្រព្រឹត្តគ្មាន ប៉ុន្តែអាការដែលប្រព្រឹត្តមាន
ព្រះនិព្វានមានប៉ុន្តែមិនមែនតួមនុស្សដែលស្វែងរកនោះទេ
ផ្លូវមាន ប៉ុន្តែមិនមែនអ្នកដំណើរដែលដើរផ្លូវនោះទេ" ៧

ត្រូវតែយល់ថាប្រស្នាដែលពោលពីរឿងព្រះនិព្វាននេះ ជាប្រស្នាពិបាកយល់បំផុតក្នុងពុទ្ធវចនៈបើទោះណាជាយើងបេះគ្នេរគ្នាន់ពិចារណាឲ្យជ្រៅទូលាយក្ដី យើងនៅតែមិនអាចនឹងយល់បានអំពីសភាពពិតប្រាកដនៃព្រះនិព្វាន ឯលំអានជាទីប្រសើរដើម្បីស្គាល់នូវព្រះនិព្វាននោះគឺត្រូវខំសង្វេគឲ្យដល់នូវព្រះនិព្វានឬបណ្ដោយឲ្យព្រះនិព្វានមកដល់យើង គេមិនអាចនឹងស្គាល់របស់១ បានដោយឥតប្រព្រឹត្តឡើយ ហើយក្នុងឋាននេះលើសកន្លែងឯទៀតទាំងអស់ ប៉ុន្តែបើព្រះនិព្វានហាក់ដូចជានៅក្នុងទីងងឹតអន្ធការឬឯផ្លូវដែលទៅកាន់ព្រះនិព្វានដែលអ្នកប្រាជ្ញាសុខទាំងឡាយ អាចនឹងទៅបានគ្រប់គ្នានោះ ព្រះសម្មាសម្ពុទ្ធជាម្ចាស់បានសំដែងដោយជាក់ច្បាស់ហើយបានយល់នូវទៅ ។

ផ្លូវដែលនាំទៅកាន់ព្រះនិព្វាននោះ គឺផ្លូវកណ្ដាលដែលបៀសបេញអំពីផ្លូវខាងទាំង ២ ផ្លូវខាង ១ គឺដែលធ្វើខ្លួនឯងឲ្យធឿយលំបាក បានសេចក្ដីឈឺចាប់ឥតប្រយោជន៍ ហើយគន្លង ១ ទៀត គឺដែលធ្វើខ្លួនឲ្យរីករាយត្រេកត្រអាលក្នុងផ្លូវកាមគុណដែលជាទីនាំឲ្យបិទផ្លូវត្រៃលក្ខណញ្ញាណ ហើយនាំឲ្យយឺតដំណើរទៅកាន់ព្រះនិព្វាន ។

កិច្ចដែលត្រូវហាត់ជាដំបូងដើម្បីដើរតាមផ្លូវធំនេះ គឺធ្វើសីល មិនត្រូវបំបាត់ជីវិតឬធ្វើទុក្ខធ្វើបាបដល់សត្វមានជីវិតឡើយ ត្រូវតាំងចិត្តឲ្យល្អហើយអាណិតអាសូរដល់សត្វទាំងអស់ ទោះជាសត្វតូចតាចដែលវារខាងក្រោមជើងយើងក្តី ត្រូវតមកុំប្រព្រឹត្តចោរកម្មក្នុងហានណាៗក្តី គឺត្រូវតាំងចិត្តជាមនុស្សសុចរិតស្លូតត្រង់គ្រប់ហាន ត្រូវតមកុំប្រព្រឹត្តកន្លងបវេណី គឺត្រូវតាំងខ្លួនឲ្យបរិសុទ្ធកុំឲ្យមានមន្ទិលអ្វី ត្រូវតមកុំពោលពាក្យភូតកុហក គឺត្រូវតែពោលនូវពាក្យដែលពិត ត្រូវជៀសវាងគ្រឿងថ្នាំ ដែលនាំឲ្យទោស គឺត្រូវកុំវះវាមក្នុងការបរិភោគ ហើយឲ្យខ្លួនជាអ្នកវៀងវៃ ។

សិក្ខាបទទាំង៥នេះ ត្រូវកាន់រក្សាឲ្យម៉ត់ចត់ ព្រោះថាបើនឹងបណ្តោយឲ្យភ្លាត់ភ្លាំងទៅ នោះនឹងនាំឲ្យអានមន្ទិលសៅហ្មងទទើសទទែង ស្មើរតែនឹងរំលងមិនផុតឡើយ ។

ត្រូវកត់សំគាល់ថា រីព្រះយោគាវចរនៅវេលាដែលកំពុងត្រាច់តាមមហាមាគ៌ានោះ ត្រូវបំរុងខ្លួនត្រៀមចាំឲ្យបរិសុទ្ធរៀបរយឲ្យទទួលនូវសេចក្តីក្រដោយចេតនា ហើយបំពេញជីវិតដោយប្រពៃ ដើម្បីទ្រទ្រង់នូវរាងកាយ កុំឲ្យសេចក្តីស្មុគនឹងសេចក្តី

សប្បាយទាញយកទៅកាន់សេចក្ដីព្រងើយកន្តើយ សេចក្ដីងងុយនឹងសេចក្ដីខ្ជិលច្រអូសបាន ។

ឯបំណែកព្រះយោគាវចរនោះ កាន់តែបំរើឧបត្ថិចម្ដង ៗ យ៉ាងជាក់ស្ដែងដោយវិបានឹងដោយកិច្ចយ៉ាងទៀងទាត់ ហើយដោយសម្ពស្ស ដែលបង្វឹកហាត់បាន ដូច្នេះហើយក៏កម្លាំងកម្មនោះបង្ខំឲ្យបោះបង់នូវតំរេកក្នុងលោកចោលហើយ ចូលកាន់ភេទអ្នកបួសវិញ ក្នុងវេលានោះក៏កើតគំនិតដូច្នេះឡើង ។

ការរស់នៅក្នុងភេទជាឃរាវាសនោះប្រកបដោយការតយុទ្ធនឹងសឹកសង្គ្រាមជាអនេក ប្រកបដោយការវេរនឹងសេចក្ដីត្រូវការឥតមានស្រាក ដែលជាទីឥតជំពាក់ទាក់ទិនហើយខ្ពង់ខ្ពស់ដូចជាអាកាសយប្រទេសនោះ គឺការរស់នៅរបស់បុគ្គលដែលឥតផ្ទះសម្បែងនោះឯង ។

លុះគិតឃើញដូច្នេះហើយ ក៏លះបង់នូវទ្រព្យសំរាប់លោកជាអសារ ដើម្បីចូលកាន់ភេទអ្នកបួស ហើយក៏សង្វាតទ្រទ្រង់នូវជីវិតដោយឥតមានមោះមន្ទិលសៅហ្មងឡើយ ដល់ទីនេះហើយក៏តាំងធ្វើនូវសីលជាន់ខ្ពស់តទៅទៀត លុះដល់ថ្នាក់ដែលបរិបូណ៌ដោយសីល ហើយដោយអំណាចផលនៃសីលនេះ ព្រះ

យោគាវចរក៏ទៅជាគ្មានអត្ថភាពក្នុងអំពើកិច្ចការផ្សេង ៗ ដែលបានធ្វើ ។

LIBRARY

ទោះកិត្តិយសក្តី ទោះភោគសម្បទក្តី ទោះកេរ្តិ៍ឈ្មោះក្តី ទោះសេចក្តីបំណោញសំរាប់លោកក្តីក៏មិនអាចនឹងឲ្យព្រះយោគាវចរឲ្យប្រព្រឹត្តអំពើអ្វី ១ ដែលជាការផ្ទុយទាស់នឹងលទ្ធិជាន់ខ្ពស់របស់លោកនោះឡើយ ។

ការរស់នៅដោយឥតបំណាងនឹងដោយឥតផ្ទះសម្បែងនោះជាផ្លូវយ៉ាងខ្លីដោយពិតប្រាកដដែលនឹងទៅកាន់ព្រះនិព្វាន. ប៉ុន្តែមិនត្រូវយល់ដោយដាច់ខាតហ៊ាបានតែបួសកាន់ភេទបព្វជិតទើបបានទីព្រះអរហន្តឡើយ ព្រោះមានគំរូជាច្រើនដែលនៅភេទជាឃរាវាស ហើយបានដល់ព្រះនិព្វាន ដោយឥតលះបង់ភេទគ្រហស្ថបោល ឧបាសកអនាថបិណ្ឌិក បានដល់សោតាបន្ន សាក្យមហានាម បានដល់សកិទាគាមិ នាយស្វនឆ្នាំងឃដិការ បានដល់អនាគាមិ ព្រះបាទសិរិសុទ្ធោទន៍ លះបង់ជីវិតក្នុងទីជាព្រះអរហន្ត ព្រះអនាគាមិ តាមធម្មតាត្រូវរស់នៅក្នុងភេទឥតភរិយា ហើយឯព្រះអរហន្តដែលមានភេទជាឃរាវាសនោះតាមក្នុងគម្ពីរថា ត្រូវបំពេញភេទជាបព្វជិតឬត្រូវចូលនិព្វាន ព្រោះថា

នឹងកាត់ភេទជាឃរាវិសរូមសុខទុក្ខ នឹងត្រួស្ទួរតទៅឲ្យហួសពីពប្លៃមិនបានឡើយដោយហេតុនេះហើយបានជាព្រះយោគាវបរដែលលោកតាំងនៅមាំក្នុងសីលល្បងកាត់ក្រឹត្យយ៉ាងខ្ពស់ តទៅទៀតគឺតាំងកាត់យកនូវសមាធិដែលជាបែបហាត់ទី២ដើម្បីទៅកាន់ផ្លូវព្រះនិព្វាន ។

សីលដែលបានហាត់បរិសុទ្ធហើយ ជាដើមអាទិ៍យ៉ាងខ្លឹមសារ ក្នុងការបំពេញនូវសមាធិ ឬកិរិយាមារយាទដែលឥតសណ្ដាប់ធ្នាប់នោះ នាំឲ្យកើតជាសេចក្ដីក្រវល់ក្រវាយឡើង តែកាលណាមានសេចក្ដីក្រវល់ក្រវាយក្នុងខ្លួនហើយ ចិត្តនោះក៏នឹងទៅរកសភាពដែលគេបោះបង់ចោលមិនរាប់អាន ក្នុង ១ ពេល ១ វេលាសិន ។

សមាធិជាកិរិយាសង្រួបសង្រួមនូវចិត្តទៅលើវត្ថុ១ ដោយលះចិត្តចេញអំពីវត្ថុដទៃផ្សេងៗ ដើម្បីនឹងតាំងនូវសមាធិនេះ ព្រះយោគាវចរត្រូវពិចារណាជាមុន ដោយពិនិត្យពិច័យនៃវត្ថុដែលនឹងយកមកសំឡឹងនោះក្នុងកម្មដ្ឋានទាំង៤០ ដែលមានសំដែងដោយល្អិតក្នុងគម្ពីរវិសុទ្ធិមគ្គ នោះត្រូវរើសយកកម្មដ្ឋានណា ១ ដែលជាទីគួរសមដល់ចរិតរបស់ខ្លួន លុះបានរើសរកជាស្រេច

ហើយ ត្រូវថយទៅនៅក្នុងទីណា ១ ដែលស្ងាត់ឥតមានអ្វីនាំឲ្យ
ទទើសទទែង ហើយរៀបចំទីបង្គុយឲ្យស្រួលកុំឲ្យរោយស្រពន់
ទើបតាំងព្យាយាមខំប្រឹងដើម្បីសង្រួមនូវចិត្តទៅកាន់វត្ថុដែលខ្លួន
ភាវនានោះ ឬដែលហៅថាកម្មដ្ឋាន បើទោះណាជាខំសង្រួមនូវ
ចិត្តទៅកាន់វត្ថុដែលជាកសិណនោះក្តី ក៏មនុស្សដែលទើបហាត់
មិនអាចនឹងជៀសវាងផុត អំពីគ្រឿងបលិពោធដំបូងបានឡើយ
អារម្មណ៍ខាងក្រៅកើតឡើងចំពោះមុខហាក់ដូចជាស្រមោលកុន
ដូច្នោះ វេលានោះចិត្តដែលមិនអំណត់ក៏កើតឡើង ដោយហេតុ
សេចក្តីចំរើនទៅខាងមុខនោះយឺតយ៉ាវពេក ដូច្នេះហើយសេចក្តី
ព្យាយាមក៏នឹងថយចុះ ឬព្រះយោគាវចរដែលបានថ្នឹកទៅហើយ
នោះតាំងចំរើនសំដៅឆ្ពោះទៅកាន់ខាងមុខគឺទៅកាន់គោលដែល
សំដៅយកតែម្តងបើទោះណាជាមានគ្រឿងបលិពោធឬនីវរណៈ
ដែលនាំឲ្យទទឹងទាស់ ក៏ខំកាប់ឆ្កាបំពានទៅ ឥតមានរាថយ
ក្រោយ ១ ស្របក់សោះឡើយ ហើយដោយអំណាចសេចក្តីជឿ
ពេញចិត្តដែលបេះតែមានបង្កើតឡើងនឹងសេចក្តីសុខដែលបេះ
តែមានថែមមកជានិច្ច នោះព្រះយោគាវចរក៏តាំងតយុទ្ធដើម្បីបំ
បាត់នូវសេចក្តីប្រាថ្នាហើយសង្រួមចិត្តទៅកាន់បរិកម្មនិមិត្តនោះ

លុះដល់ជ្រៅជ្រះបស់សព្វមូលអារម្មណ៍ល្អ ហើយអារម្មណ៍ដែលផ្សេងៗទៀតក៏កំចាត់ចេញបានពីក្នុងចិត្តជាស្រេចខណៈកាលណាបានឃើញនូវកសិណ គឺបានដល់នូវគោលបំផុតនេះហើយ ក្នុងហេតុនេះគឺកសិណនោះឯងជាវត្ថុដែលមានរូបធម្មតា ឯចំណែកខាងរូបដែលឃើញដោយនិមិត្តវិញ (ឧគ្គហនិមិត្ត) នោះគឺជារូបប្រាកដក្នុងចិត្ត មានភាពស្លានដូចគ្នានឹងកសិណ ដែលមានរូបតាមធម្មតាមែនៗ គឺនិមិត្តនោះបង្កើតឲ្យឃើញនៅក្នុងចិត្តឡើងលុះដល់និមិត្តនោះប្បាស់ប្រាកដទៅក្នុងមនោទ្វារតែម្យ៉ាង (បដិភាគនិមិត្ត) ហើយព្រះយោគាវចរបរិកម្មតៗ ទៅទៀត ដោយប្រុងស្មារតីយ៉ាងម៉ឺតបត់ទៅកាន់និមិត្តដែលកើតឡើងនោះក៏បានឈ្មោះហៅថាដល់នូវឧបចារសមាធិ ឯចំណែកនីវរណៈទាំង៥ដែលជាធម៌ជំទាស់នូវសេចក្ដីចំរើនពោលគឺសេចក្ដីប្រាថ្នាសេចក្ដីងងុយ សេចក្ដីចងចិត្តគុំគួន សេចក្ដីរសាប់រសល់ សេចក្ដីសង្ស័យនោះកើតមានឡើងដោយពេលដោយ១ណៈលំដាប់នោះក៏បានដល់នូវអប្បនាសមាធិ ហើយដោយសេចក្ដីត្រេកអរផតប្រៀបព្រះយោគាវចរក៏បានដល់ក្នុងឈានសោយនូវសេចក្ដីសុខនឹងសេចក្ដីសំរាន្តរបស់ចិត្ត ដែលមានគោលតែមួយចំពោះមុខ១ៗ

លុះកាលណាព្រះយោគាវចរបានបង្ហាត់នូវចិត្ត បានបទ១ បែបហើយក៏អាចនឹងបំរើននូវអភិញ្ញាទាំង ៥ បាន់ឥតមានទើស ទាស់អ្វីឡើយ ឯអភិញ្ញាទាំង៥ នោះគឺ ទិព្វចក្ខុ ១ ទិព្វសោត១ បុព្វេនិវាសានុស្សតិញ្ញាណ១ បរចិត្តវិជ្ជានន: ១ នឹងឥទ្ធិវិធ: ១ ។

ឯសមាធិនឹងអភិញ្ញានោះ មិនមែនសុទ្ធតែមានប្រយោជន៍ ដោយជាប់ខាតក្នុងការដែលបានដល់នូវព្រះអរហត្តឡើយ ពិត មែនតែជាមេយ៉ាងវិសេសរបស់អ្នកដែលបាន បានជាថាដូចនេះ ព្រោះនៅមានព្រះអរហន្តដែលជាសុក្ខវិបស្សក:ដែលលោកបាន ដល់ព្រះអរហត្តដោយគ្រាន់តែធ្វើចិត្តខាងក្នុងឲ្យស្ងួតស្ងប់ប៉ុណ្ណោះ ឥតបានពឹងផ្អែកទៅលើសមាធិឡើយ បើទោះណាជាក្នុងឋាន នេះចិត្តរបស់ព្រះអរហន្តនោះបរិសុទ្ធយ៉ាងណាក្តី ហើយបើទោះ ណាជាលោកមិនទាន់រួចជាស្រឡះអំពីអំណាចសេចក្តីប្រាថ្នានៅ ឡើយក្តី ព្រោះថាដោយអំណាចសេចក្តីសង្រួមនោះ ចិត្តដែល អាក្រក់នោះនឹងដេញបេញបាន ដោយពេលដោយខណ: ចិត្ត អាក្រក់នេះអាចនឹងកើតឡើងវិញបាន នៅវេលាដែលធ្វេសប្រ- ហែសក្នុង ១ ពេលៗ ។

វិរិយៈអាចតម្រង់នូវសំដីនឹងអំពើរបស់យើង ឯចំណែក សេចក្ដីសង្រួមអាចតម្រង់នូវចិត្តរបស់យើង ប៉ុន្តែគឺបញ្ញាដែល ជាសភាពទី ៣ ឬទីបំផុត ដែលអាចនឹងនាំឲ្យកំចាត់ដោយដាច់ ខាតនូវសេចក្ដីប្រាថ្នា ដែលសមាធិបានឃាត់ទុក ។

ជាដើមត្រូវពិចារណានូវវិសុទ្ធិញាណ គឺសេចក្ដីឃើញ ដោយបរិសុទ្ធិ ដើម្បីឲ្យយល់ច្បាស់នូវវត្ថុនីមួយយ៉ាងពិតប្រាកដ. គឺបើពិតឃើញថាពិត មិនពិតឃើញថាមិនពិត ដោយអំណាច ចិត្តដែលត្រាប់ផ្ដោះទៅកាន់កសិណតែមួយ ព្រះយោគាវចរក៏ពិ- ចារណាដោយពិនិត្យផ្ចិតផ្ចង់នូវឥន្ទ្រិយរបស់លោក លុះពិចារ- ណាដូចនេះហើយ ក៏ឃើញថាឥន្ទ្រិយរបស់លោកមិនមែនអ្វីក្រៅ អំពីប្រជុំនាមធម៌នឹងរូបធម៌ឡើយ ឯនាមធម៌នោះគឺជាអារម្មណ៍ ផ្សេងៗ ដែលកើតឡើង ដោយការប៉ះពាល់នៃខន្ធជាមួយនឹង កំលាំងឫទ្ធិរបស់ខន្ធ ឯចំណែករូបធម៌វិញនោះ គឺជាកម្លាំងនឹង លក្ខណៈដែលកើតឡើងជាភាពសណ្ឋានផ្សេង ។

លុះដល់បានឃើញច្បាស់នូវជាតិរបស់ខ្លួន ដោយឥត មានភាន់ច្រឡំដូច្នេះហើយ ក៏តាំងល្បងរកនូវដើមកំណើតរបស់ ឥន្ទ្រិយទៀត ព្រមទាំងអត្តភាព ក្នុងសណ្ឋាននេះព្រះយោគាវចរ

ឃើញច្បាស់ថា វត្ថុទាំងអស់ដែលមានក្នុងលោកនេះព្រមទាំងអាត្មាឯងផង សុទ្ធតែកើតមកអំពីហេតុ ១ ឬហេតុច្រើនក្នុងកាលជាអតីតឬបច្ចុប្បន្ន ហើយឯជាតិរបស់ខ្លួននេះកើតមកអំពីហេតុជាអតីតពោលគឺសេចក្ដីល្ងង់ (អវិជ្ជា) សេចក្ដីប្រាថ្នា (តណ្ហា) ការភ្ជាប់ចិត្ត (លោភ) អំពើ (កម្ម) នឹងគ្រឿងទ្រទ្រង់ជីវិត (អាហារ) ដោយហេតុទាំង ៥ នេះហើយ ទើបត្តអត្តភាពកើតឡើងបាន ហើយដោយអំពើពីអតីតនាំមកនូវបច្ចុប្បន្ន រីអំពើជាបច្ចុប្បន្នក៏នឹងតាក់តែងនូវអនាគតតៗទៅផ្លូវនេះឯង លុះបានពិចារណាផ្លូវនេះហើយ ព្រះយោគាវចរក៏អស់សេចក្ដីមន្ទិលសង្ស័យអំពីអតីត បច្ចុប្បន្ន នឹងអនាគតតទៅ ។

លំដាប់នោះក៏ពិចារណាឃើញថា វត្ថុដែលកើតឡើងដោយហេតុសុទ្ធតែជារបស់មិនទៀងមិនថាវរៈ (អនិច្ចំ) សុទ្ធតែប្រកបដោយឈឺចាប់ (ទុក្ខ) សុទ្ធតែឥតខ្លឹមសារឬមិនមានសេចក្ដីតាំងនៅអស់កាលជានិច្ច (អនត្តា) នៅវេលាណាដែលព្រះយោគាវចរក្រឡេកទៅជុំវិញខ្លួននោះ មិនមានប្រទះអ្វីក្រៅអំពីត្រៃលក្ខណ៍នេះឡើយ គឺឃើញក្រឡេកតបំពោះភ្នែក លោកឃើញច្បាស់ថាជាតិរបស់មនុស្សនេះគ្រាន់តែជាផ្លូវជាទីគោចរជាពេលឬនកាស

ដែលនៅជាតំណជាប់តទៅឥតមានដាច់ប៉ុណ្ណោះ ទោះនៅលើមេឃក្តី លើផែនដីក្តី មិនអាចនឹងបង់សេចក្តីសុខដែលជាពិតប្រាកដនោះបានឡើយ ដោយហេតុថា សេចក្តីតំរេកត្រេកត្រអាលគ្រប់ឋានសុទ្ធតែជាដើមអាទិនៃទុក្ខទាំងអស់ អ្វីដែលជាបណ្តោះអាសន្ន សុទ្ធតែប្រកបដោយទុក្ខហើយ តែកាលណាមានសេចក្តីប្រែប្រួលផ្លាស់ប្តូរនឹងសេចក្តីឈឺចាប់កើតញយ ៗ ហើយនោះមិនអាចនឹងមាននូវឥន្ទ្រិយដែលជាទៀងបានឡើយ។

លុះបានជ្រាបចូល ឬជក់ចូលទៅ ក្នុងការភាវនាដ៏ជ្រៅហើយ ព្រះយោគាវចរក៏នឹងភ្ញាក់ខ្លួនក្នុងវេលាណាមួយមិនខាន គឺនឹងបានឃើញនូវរស្មីចេញពីខ្លួន ក្នុងឋាននេះហើយដែលបានសោយនូវសេចក្តីសុខដែលមិនដែលមាននឹងបានក្រេបនូវសេចក្តីសប្បាយ សេចក្តីក្សេមក្សាន្តដែលមិនដែលប្រទះម្តងសោះ ។

លំដាប់នោះក៏សេចក្តីជ្រះថ្លាសទ្ធាបំរើនច្រើនឡើង ហើយឯសេចក្តីដែលពេញចិត្តនោះក៏ស្អាតល្អ ឥតមានមន្ទិលសៅហ្មងព្រមទាំងសេចក្តីឃើញខាងក្នុងក៏ច្បាស់ជាប់នៅជានិច្ច ហើយក៏ស្មានថាខ្លួនបានដល់ទីព្រះអរហន្តហើយ ព្រោះបានឃើញនូវរស្មីនោះ តែមិនមែនដូចជាស្មាននោះឡើយ ក្រោយនោះបន្តិចក៏

យល់ឡើងថា សេចក្ដីដែលឃើញទាំងប៉ុន្មាននេះសុទ្ធតែជាការ លល្បងនាំឲ្យខុសពីសេចក្ដីឃើញខាងក្នុងនោះទេ តាមការពិត នោះមិនទាន់បានដល់ថ្នាក់ព្រះអរហត្តឡើយ យល់ដូចនេះ ហើយក៏ប្រឹងព្យាយាមកត់សំគាល់នូវផ្លូវត្រូវនឹងផ្លូវខុស ។

លុះកាលណាបានប្រទះផ្លូវត្រូវហើយ ក៏តាំងសមាធិជាថ្មី អំពីសេចក្ដីកើតនឹងសេចក្ដីរលត់ទៅវិញ នៃវត្ថុមួយដែលតាក់ តែងឡើង សមាធិនេះហើយដែលនាំឲ្យកើតជ្រះថ្លាជាច្រើន ព្រោះសេចក្ដីដែលប្រែប្រួល ឬសេចក្ដីរលត់នោះឃើញច្បាស់ ប្រាកដជាងសេចក្ដីដែលបដិសន្ធិឡើង ។

ដោយហេតុនេះហើយទើបព្រះយោគាវចរផ្ចង់ស្មារតី ទៅ កាន់សេចក្ដីរលាយរលត់នៃវត្ថុនីមួយៗ លំដាប់នោះក៏បានយល់ ច្បាស់នូវនាមធម៌នឹងរូបធម៌ ដែលធ្លាប់បានជាតួអត្តភាពឡើងនេះ នៅក្នុងសភាពដែលមានធម្មតា ត្រូវប្រែប្រួលផ្លាស់ប្ដូរជានិច្ចឥត ស្រាក មិនអាចនៅដដែលបាន ពីពេល ១ ទៅពេល ១ ឡើយ

ដូចនេះហើយក៏កើតនូវប្រាជ្ញាថ្លាស្គាល់ច្បាស់ថាវត្ថុទាំងឡាយ ដែលកើតឡើងហើយរលាយទៅវិញនោះជាការគួរស្ញើមណាស់ លោកជាតុទាំងមូល ឃើញដូចជាទីគរច្បងដែលឆេះសន្ធោសន្ធៅ

នឹងជាទីកំណើតនៃសេចក្ដីគ្រោះកាចអន្តរាយទាំងអស់ ហើយក៏តាំងពិចារណាអំពីទុក្ខវេទនា នឹងសេចក្ដីប្រលោមរបស់លោកដែលគួរខ្លាចនេះ លំដាប់នោះក៏តាំងតែខ្ពើមនូវលោក ហើយក៏មានប្រាថ្នានឹងគេចចៀសឲ្យបាន ដោយអាស្រ័យគោលរបស់ចិត្តនេះ ទើបតាំងសមាធិជាថ្មីទៀតអំពីព្រះត្រៃលក្ខណ៍ រួចពីនេះក៏តាំងកើតចិត្តស្មើទូទៅលើវត្ថុដែលតាក់តែងឡើង គឺមិនស្រឡាញ់មិនស្អប់វត្ថុនានា ដែលនៅលើដី លុះចាប់ថ្នាក់នេះបានហើយព្រះយោគាវចរក៏តាំងរើសយកនូវលក្ខណៈណាមួយដែលពេញចិត្តជាងគេជាគោលក្នុងលក្ខណៈទាំង៣ នោះហើយក៏តាំងសង្រួមចិត្តដោយប្រុងប្រយ័ត្នដើម្បីឲ្យកើតឡើងនូវសេចក្ដីឃើញខាងក្នុងៗផ្លូវនេះ ជិរាបដល់ទល់នឹងថ្ងៃជ័យមង្គល គឺថ្ងៃដែលបានសេចក្ដីក្សេមក្សាន្តឥតរលត់ ក្នុងឋាននេះហើយដែលបានប៉ះពាល់យល់នូវព្រះនិព្វានជាដំបូងបំផុតក្នុង ១ ជាតិនេះ ។

"ឧបមាដូចជាអ្នកដើរក្នុងវេលាយប់ ដែលបានប្រទះឃើញនូវភូមិប្រទេសជិតខាងខ្លួនក្នុងវេលាផ្លេកបន្ទោរមួយភ្លែតៗហើយរូបភាពដែលបានឃើញនោះក្នុងពេលក្រោយតពីនោះយូរមក ក៏នៅចាំប្រាកដទោមុខបានយ៉ាងណា រីព្រះយោគាវចរដែលមាន

ពន្លឺផ្ទះខាងក្នុងក៏ឃើញព្រះនិព្វាន ហើយហាំបានជាប្រាកដនឹងភ្លេចយ៉ាងនោះឯង" កាលណាដែលបានប្រទះឃើញនូវព្រះនិព្វានជាដំបូងម្ដងម្នេះ គេហៅថាជាព្រះសោតាបន្ន គឺថាជាអ្នកចូលក្នុងប្រឡាយឬខ្សែទៅកាន់ព្រះនិព្វានព្រះសោតាបន្នវៀរផុតអំពីចំណង ៣ គឺសក្កាយទិដ្ឋិ សេចក្ដីប្រកាន់ខ្លួនប្រាណ១ វិចិកិច្ឆាសេចក្ដីសង្ស័យ១ សីលព្វត សេចក្ដីអាធ្យាស្រ័យក្នុងរបៀបពិធីបុណ្យផ្សេងៗដែលខុសបាកពុទ្ធសាសនា១ ដោយព្រះសោតាបន្នមិនទាន់ទំលាយបង់នូវសេចក្ដីប្រាថ្នាក្នុងការរស់នៅក៏នឹងកើតយ៉ាងច្រើនពជាតិទៀតក្នុងជាតិខាងមុខនោះព្រះសោតាបន្នអាចនឹងចាំឬនឹងមិនចាំបានថា ខ្លួនលោកជាសោតាបន្ន ប៉ុន្តែលោកគង់មានលក្ខណៈបែបជាអ្នកជឿបុណ្យជឿបាប ។

ព្រះសោតាបន្នមានសេចក្ដីជឿដោយពេញទី ក្នុងព្រះពុទ្ធព្រះធម៌នឹងព្រះសង្ឃ ហើយគ្មានអ្វីនឹងអាចនាំឲ្យប្រព្រឹត្តបំពានលើសិក្ខាបទទាំង៥ឡើយក្រៅពីនោះទៀតព្រះសោតាបន្នលោកផុតអំពីឧប្បត្តិហេតុជាស្រទប្បៈ ព្រោះខ្លួនលោកមានដំណើរទៅកាន់សេចក្ដីត្រាស់ដឹង លោកតាំងប្រមូលផ្ដុំនូវកម្លាំងថ្មីគឺសេចក្ដីក្លាហាន ដែលជាផលនៃសេចក្ដីប្រទះឃើញព្រះនិព្វានអំពី

បម្វាយ សេចក្ដីចំរើននឹងកើតឡើងដោយស្របហ៍សធាប់ ហើយលោកក៏តាំងចំរើនដោយមិនបត់ថ្មិតថ្មិងដរាប លុះដល់សេចក្ដីយើញខាងក្នុងរឹងរឹតតែបារវៈមាំមួនឡើងគ្រាតែបានដល់ថ្នាក់ជាព្រះសកទាគាមិ ដែលត្រូវកើតវិញម្ដងទៀតក្នុងមនុស្សលោក ហើយបន្ថយធមិ២ផ្សេងទៀតគឺសេចក្ដីប្រាថ្នាក្នុង១ខ្លួននឹងបេតនាអាក្រក់ បានជាបានតាមបាព្រះសកទាគាមិព្រោះបានឹងមកកើតក្នុងលោកនេះ១ជាតិទៀតក្នុងហាដែលជាតិនេះមិនបានសំរេចព្រះអរហត្តផល ។ គួរតែសំគាល់ទុកបាព្រះយោគាវចរដែលបានដល់ថ្នាក់ទាំង២នេះហើយ គ្រាន់តែជាអ្នកអាចនឹងបន្ថយនូវបំណង ២ យ៉ាងមាំដែលបងរឹតរួតខ្លួន តាំងពីក្នុងកាលជាអតីតដែលកន្លងមកយូរហើយនឹងហាំមិនបាន ហើយគ្មានដើមទងប៉ុណ្ណោះ ជួនកាលក៏កើតនូវសេចក្ដីក្រវល់ក្រវាយ ទៅកាន់រាគៈតណ្ហានឹងសេចក្ដីក្រោធខ្លះដែរ ប៉ុន្តែសេចក្ដីក្រវល់ក្រវាយនេះមានសណ្ឋានស្តួចស្តើងណាស់ ។

លុះកាលណាបានដល់ថ្នាក់ទី ៣ គឺអនាគាមិដែលមិនត្រឡប់មកកើតលើដីវិញសោះ នោះទើបបានរួបផុតស្រឡះអំពីបំណងដែលយើងពោលហើយខាងលើ ព្រះអនាគាមិមិនវិលមក

កើតក្នុងមនុស្សលោកវិញឡើយ ហើយមិនត្រូវការឬមិនប្រាថ្នាទៅយកកំណើតក្នុងលោកជាតុផ្សេងដទៃឯណាទៀតទេ តាំងអំពីពេលដែលបានផ្ដាច់ឫស នៃសេចក្ដីប្រាថ្នាក្នុងកិលេសកាមមក លុះទំលាយខន្ធទៅ ក៏ទៅបដិសន្ធិក្នុងភពដែលបរិសុទ្ធ (សុទ្ធាវាស) ដែលជាកន្លែងបំរុងទុកសម្រាប់តែព្រះអនាគាមិនឹងព្រះអរហន្តប៉ុណ្ណោះ ទោះជាព្រះអនាគាមិដែលមិនទាន់អស់ប្រាថ្នានឹងកើតទៀតក៏ដោយ ។

ក្នុងវេលានេះព្រះយោគាវចរ ដែលមានសេចក្ដីក្លាហានដោយជ័យជំនះរបស់សេចក្ដីព្យាយាម ក៏តាំងធ្វើឲ្យសម្រេចនូវថ្នាក់បំផុត ដោយកំចាត់បង់នូវបំណងទាំង ៥ ដែលជាបំណងខាងចុងបំផុត គឺរូបរាគ ១ អរូបរាគ ១ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ នឹងមោហៈ ១ ហើយក៏បានដល់នូវព្រះអរហត្តផលមួយរំពេចៗ ក្រោយនោះក៏បានយល់ប្រាកដថាការដែលត្រូវធ្វើនោះយ៉ាងជួបម្ដេចខ្លះ ថាទុក្ខដែលយ៉ាងធ្ងន់ជាបំផុតនោះបានបៀសវាងផុតស្រឡះហើយ ។ ថា សេចក្ដីប្រាថ្នាឬបេតនាចង់រស់ គ្រប់ស្ថាននោះ បានទំលាយបោលជាស្រឡះហើយ លំដាប់នោះព្រះយោគាវចរតាំងនៅក្នុងទីខ្ពស់ជាងវិមានទិព្យទៅទៀត ហើយ

ឆ្ងាយផុតវិស័យអំពីកាមរាគនឹងកិលេសក្នុងលោកនេះ តាំងព្រេបនូវវិមុត្តិរសដែលទៀងជានិច្ចឥតប្រៀបបាននៃព្រះនិព្វាន។

ប៉ុន្តែបើទោះណាជាយ៉ាងដូច្នេះក្តី ក៏ព្រះអរហន្តទាំងឡាយមិនដែលបៀសឡផុតអំពីសេចក្តីឈឺចាប់នៃសព៌ាង្គកាយឡើយ ព្រោះលោកនៅជាប់បំពាក់ក្នុងរូបមនុស្សលោក ។

ដូច្នេះហើយទើបឃើញថាព្រះនិព្វាននេះនឹងបានជាប្រាកដក្នុងពេលណាមួយ ហើយបំណែកសេចក្តីដែលរួចផុតអំពីសេចក្តីឈឺចាប់របស់រូបនេះ នឹងបានក្នុងពេលក្រោយដែលទំលាយខន្ធទៅ ។

គួរតែសំគាល់ក្នុងស្ថាននេះថា ព្រះអនាគាមិនឹងព្រះអរហន្តដែលលោកបានបំរើននូវសមថភាវនា ឬបើនឹងពោលបែបម្យ៉ាងទៀតថា ដែលលោកបានបំពេញកិច្ចសង្រួមចិត្តព្រមទាំងបានធ្វើឈានបែបផ្សេងៗជាច្រើនហើយនោះ លោកអាចនឹងសោយនូវវិមុត្តិរសនៃព្រះនិព្វានបានក្នុងជាតិនេះ ត្រង់នេះហើយដែលហៅថានិរោធសមាបត្តិ ។ ក្នុងវេលាដែលចូលនិរោធសមាបត្តិនោះមានស្ថានដូចជាមនុស្សដែលភ្លឹកស្មារតី ឬដេកលក់សិប់ដូច្នោះក្នុងពេលនេះរូបកាយជាប់ខាតស្រឡះអំពីសេចក្តីឈឺចាប់ហើយ

បំណែកអារម្មណ៍ផ្សេងៗ ក៏ឈប់ទាំងអស់ ។ តាមខាងព្រះពុទ្ធសាសនា ស្ថាននេះហើយ ដែលជាបែបយ៉ាងឧត្តមបំផុតរបស់សេចក្ដីសុខ ដែលសោយក្នុងជាតិនេះ ។

ក្នុង ពាហុវេទនិយសូត្រ ព្រះសម្មាសម្ពុទ្ធបានសំដែងអំពីសភាពនៃសេចក្ដីសុខទាំង ១០ យ៉ាង រាប់រៀបតាំងអំពីសេចក្ដីសុខធម្មតាដែលគ្រោតគ្រាតឡើងទៅ ហើយល្អិតណាតែគេឡើងខ្ពស់បន្តិចៗ ទៅក្នុងផែនទីឬហាត់ដោយនៃចិត្ត ក៏សេចក្ដីសុខនេះ ទៅជាសុខយ៉ាងថ្លៃថ្លា យ៉ាងប្រសើរថ្លៃថ្លា យ៉ាងល្អិតផ្ទួរផង់ គ្រាតែមនុស្សទាំងឡាយក្នុងលោកនេះមិនដែលបានស្គាល់ជាយ៉ាងដូចម្ដេចម្ដងសោះឡើយ ។

ក្នុងបឋមជ្ឈាននេះ ព្រះយោគាវចរសោយនូវសេចក្ដីសុខក្នុងចិត្តដែលជាសេចក្ដីសុខមិនលុះក្នុងអំណាចខន្ធទាំង៥ហើយដែលជាសេចក្ដីសុខតែងកើតឡើងដោយអាស្រ័យហេតុលះបង់នូវសេចក្ដីប្រាថ្នាឬបំណងក្នុងវត្ថុកាម ។ ឯក្នុងបតុត្ថជ្ឈានវិញនោះ សេចក្ដីសុខបែបនេះ លោកបោះបង់ចោល ព្រោះថាជាសេចក្ដីសុខយ៉ាងកគ្រោតកគ្រាតវិញ មិនជាសេចក្ដីសុខ

ដែលមានផលប្រយោជន៍ឡើយ គឺលោកយកនូវសេចក្ដីស្ងើបចិត្តមកតាំងឲ្យឈ្មោះថាជាសេចក្ដីសុខវិញ ។

ព្រះសម្មាសម្ពុទ្ធបានកំណត់ទុកថា បែបភាពនៃសេចក្ដីសុខទាំងអស់ គឺសេចក្ដីសុខទី ១០ មានបែបភាពខ្ពស់ហើយថ្លៃថ្លាប្រសើរជាងទាំងអស់ ។ ក្នុងស្ថាននេះមានពាក្យទូលសួរព្រះសម្មាសម្ពុទ្ធថា ដូចម្ដេចក៏ហៅថាសេចក្ដីសុខបាន បើគ្មានចិត្តនឹងចេតសិកជាសភាពដែលត្រូវដឹងទេ។គ្រានោះព្រះសាស្ដាចារ្យទ្រង់តបប្រស្នាវិញថា "ម្នាលភិក្ខុទាំងឡាយ ដែលព្រះអរហន្តលោកសោយនូវសេចក្ដីសុខនោះ លោកមិនមែនសោយដោយអាស្រ័យសម្ផស្សឡើយ ប៉ុន្តែអ្នកទាំងឡាយត្រូវដឹងថា តាមតែនៅកន្លែងណាក៏ដោយ ឲ្យតែជាកន្លែងដែលគេបានដល់នូវសេចក្ដីសុខគឺកន្លែងនោះឯងហើយដែលព្រះអរហន្តលោកជ្រាបច្បាស់នៅសេចក្ដីសុខ " ។

អំពីសេចក្ដីដែលឲ្យឈ្មោះនៃការឈប់កំរើក ឬឈប់ត្រាច់របស់ធាតុថាជាសេចក្ដីសុខតាមភាសា ដែលប្រឌិតឡើងដោយគ្មានពាក្យនឹងអធិប្បាយ នេះជាការត្រូវបំផុតណាស់ ។

ចុះហេតុអ្វីបានជាព្រះអរហន្តលោកនៅរស់តទៅទៀត ក្នុងពេលដែលលោកបានសម្រេច នូវសេចក្តីយល់ស្ដែងរបស់ព្រះនិព្វានហើយ ឬបើនឹងពោលបែបម្យ៉ាងទៀតថា នៅវេលាដែលលោកបោះបង់គំនិតឬចេតនាចង់រស់ជាស្រេឡះហើយ? បានជាលោកនៅរស់តទៅ ព្រោះហេតុកម្លាំងកម្មរបស់លោក ដែលនាំលោកមកបដិសន្ធិនោះមិនទាន់អស់នៅឡើយៗក្នុងស្ថាននេះអ្នកប្រាជ្ញអាល្លឺម៉ង់ឈ្មោះធូប៉េនហ្វអែរ បានពោលថា មានគួរនាដូចជាកង់របស់ជាងស្មូនឆ្នាំងដែលជាងស្មូនឆ្នាំងទើបនឹងដកដៃខ្លួនចេញមកៗ ឬបើយើងទាញយកសេចក្ដីប្រៀបធៀបយ៉ាងសំខាន់ដែលមានពោលក្នុងគម្ពីររបស់យើងក៏បាន ដូចយ៉ាងសេចក្ដីដែលធៀបថា ព្រះអរហន្តមានសភាពដូចជាមែកឈើដែលបាក់ជាប់ពីដើមមក គឺមែកឈើនោះមិនអាចនឹងមានសន្លឹកស្រស់ ឬមានផ្កាផ្លែឡើយ ព្រោះមែកឈើនោះឯងមិនបានទទួលរសជាតិអាហារអំពីឫសកែវរបស់ដើមឈើមក ប៉ុន្តែគ្រឿងស្រស់ដែលមានជាប់ស្រាប់ក្នុងមែកនេះ អាចនឹងទ្រទ្រង់នៅបានជរាបដល់ពេលដែលជីវិតនៃមែកនោះលះបង់ចោលមែកនោះឯង ឯព្រះអរហន្តលោករស់នៅតទៅ តែត្រឹមកំណត់ដែលជីវិតផ្ដើយ

របស់លោកផុតរលត់ប៉ុណ្ណោះ លោកពិតគ្មានសត្វកម្មថ្មីមកបញ្ចូលទៀតឡើយ គឺលោកផុតស្រឡះពីអំពើអ្វីទាំងអស់ ទោះរូបលោកនៅរស់ក្ដី រូបរលាយទៅក្ដី ។

ខាងក្រោយនិព្វានហើយ តើព្រះអរហន្តលោកទៅជាអ្វីទៅ? ទៅជាដូចម្ដេចទៅ? ក្នុងស្ថាននេះព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថា "មានឧបមាដូចអណ្ដាតភ្លើងដែលខ្យល់បក់រេបុះឡើងពីខាងស្ដាំខាងឆ្វេងហើយរលត់បាត់ទៅយ៉ាងណា រីព្រះអរហន្តដែលលោករួចស្រឡះអំពីនាមធម៌នឹងរូបធម៌ ក៏បាត់ឥតមានសល់អ្វីនៅវេលាដែលលោកទំលាយខន្ធ មានឧបមេយ្យដូច្នេះឯង" ។

ត្រង់នេះមានបុច្ឆាសួរថា "គ្រាន់តែបាត់ទៅប៉ុណ្ណោះទេ ឬក៏មិនមានសល់អ្វីផង? "

ព្រះសម្មាសម្ពុទ្ធបរមគ្រូបានសំដែងទុកក្នុងគម្ពីរសុត្តនិបាតថា (បំណែកអ្នកដែលបាត់ទៅនោះ មិនមានរូបភាពអ្វីម្យ៉ាងល្មមឲ្យសំគាល់បានថានៅមានឡើយ ព្រោះមិនមានសល់អ្វីសោះ) តែកាលណារំលត់នូវសង្ខារបានហើយ រីនាមធម៌នឹងរូបធម៌ក៏បៀសវាងចេញឆ្ងាយផង ដូចមានឧទាន ១ សំដែងថា៖

នុំមាធ្វើជាភ្លើងអាចម៍ដែកដែលខ្ទាតចេញទៅហើយរលត់ តៗគ្នា ហើយបាត់ទៅឥតមាននរណានឹងដឹងថាទៅឯណា មាន ប្រការយ៉ាងណា រីឯលោកដែលបានរួចខ្លួនស្រឡះ ដែលបាន ឆ្លងផុតអំពីខ្សែទឹក ពោលគឺភាគតណ្ហានេះហើយ ហើយដែល បានចូលទៅក្នុងទីសុខក្សេម ក៏ឥតមានសល់ជានជាទីសំគាល់ មានប្រការយ៉ាងនោះឯង ៖

ប្រសិនបើនឹងអធិប្បាយក្នុងទីនេះ អំពីប្រស្នានឹងវិសជ្ជនា របស់ព្រះសម្មាសម្ពុទ្ធជាបរមគ្រូនឹងវច្ឆគោត្តម អំពីរឿងដដែល នេះឃើញថា ប្រហែលមិនជាទាស់នឹងទំនងលំអានសេចក្ដី ប៉ុន្មានឡើយ ។

គ្រានោះវច្ឆគោត្តមតាបស បានចូលទៅកាន់សំណាក់ព្រះ សព្វញ្ញុតញ្ញូហើយ ក៏ទូលសួរថា

បពិត្រព្រះគោត្តម ភិក្ខុដែលរួចផុតអំពីបេតនាចង់កើត ទៀតនោះ នៅក្នុងទីណា ?

សេចក្ដីត្រង់នេះគឺតាបសនេះឯង ចង់សួរអំពីព្រះអរហន្ត ។

ព្រះសម្មាសម្ពុទ្ធតបប្រស្នាវិញថា ម្នាលវច្ឆៈ ក្នុងស្ថាននេះ នឹងថាលោកវិលមកកើតវិញក៏មិនត្រូវ ។

- បពិត្រព្រះគោតម បើវច្ឆគោត្រសួរថាមានតែលោកត្រឡប់កើតផង នឹងមិនត្រឡប់កើតផងជាមួយគ្នាឬអ្វី?

- ម្នាលវច្ឆ: នឹងថាត្រឡប់កើតផងមិនត្រឡប់កើតផងតែម្តងជាមួយគ្នាក៏មិនត្រូវ ។

- បពិត្រព្រះគោតម បើវច្ឆគោត្រសួរថាមានតែលោកមិនវិលកើតផង នឹងមិនមិនវិលកើតផងឬអ្វី?

- ម្នាលវច្ឆ: ដែលថា លោកមិនវិលកើតផង នឹងមិនវិលកើតផងនោះមិនត្រូវឡើយ ។

- ឯវច្ឆតាបសដោយវិលវល់ទាល់ប្រាជ្ញា នឹងពាក្យដែលគ្មានន័យវច្ឆគោត្រក៏ពោលឡើងថា៖

- បពិត្រព្រះគោតម រឿងនេះខ្ញុំមិនដឹងពិចារណាដូចម្តេចឡើយហើយខ្ញុំវិលវល់ពន់ពេកណាស់ ។

- ម្នាលវច្ឆ: ចូរអ្នកឈប់សិន កុំអាលតាំងចិត្តស្មោះ ថាមិនដឹងគិតដូចម្តេច ហើយកុំអាលវិលវល់នឹងរឿងនេះពេក នែវច្ឆ: ព្រះធម៌នេះជ្រាលជ្រៅណាស់ មានអាថ៌កំបាំងហើយលំបាកនឹងយល់ តែមានរសពិសារណាស់ មានតែមនុស្សដែលមានប្រាជ្ញាស្មារតីវៀងវៃល្អិត ទើបអាចនឹងចាប់បាន ហើយជាធម៌យ៉ាង

លំបាកបំផុតដល់អ្នកដែលនឹងរៀន ព្រោះខ្លួនអ្នកជាពួកផ្សេង ខ្លួនអ្នកមានជំនឿផ្សេង មានវិន័យផ្សេង ហើយអង្គុយនៅជើងគ្រូផ្សេង ។

ដោយហេតុនេះ វច្ឆៈ តថាគតសូមសួរអ្នកបន្តិច ចូរអ្នកឆ្លើយតាមសេចក្ដីយល់ឃើញរបស់អ្នក ឧបមាថាបើជាភ្លើងកំពុងឆេះបំពោះមុខអ្នក តើអ្នកដឹងបាន យល់បានថាភ្លើងឆេះបំពោះមុខអ្នកឬទេ ក្នុងស្ថាននេះតើអ្នកគិតដូចម្ដេច ។

- បពិត្រព្រះគោតម ប្រសិនបើមានភ្លើងឆេះបំពោះមុខខ្ញុំៗនឹងដឹងបាន ។

- ប៉ុន្តែប្រសិនបើមានគេសួរអ្នកថា ភ្លើងដែលឆេះបំពោះមុខអ្នកនោះអាស្រ័យដោយអ្វី តើអ្នកឆ្លើយដូចម្ដេច វច្ឆៈ ។

- បពិត្រព្រះគោតម បើមានគេសួរដូច្នេះ ខ្ញុំនឹងឆ្លើយថាភ្លើងដែលឆេះបំពោះមុខខ្ញុំនេះអាស្រ័យដោយការបង្កាត់ឧសនឹងស្មៅ

- ម្នាលវច្ឆៈ បុះប្រសិនបើភ្លើងដែលឆេះនៅបំពោះមុខខ្លួននេះរលត់ទៅវិញ តើអ្នកដឹងថាភ្លើងនោះរលត់ឬទេ ។

- បពិត្រព្រះគោតម ប្រសិនបើភ្លើងដែលឆេះនៅមុខខ្ញុំនេះរលត់ទៅ ខ្ញុំដឹងបានថាភ្លើងនោះរលត់ ។

- ម្នាលវច្ឆៈ បុះប្រសិនបើមានគេដណ្ដឹងសួរអ្នកថា បុះភ្លើងដែលរលត់ទៅនោះទៅកាន់ទីណា ទៅខាងកើត ខាងលិច ខាងជើង ឬខាងត្បូង តើក្នុងប្រស្នានេះអ្នកនឹងឆ្លើយប្រាប់គេថាដូចម្ដេច ?

- បពិត្រព្រះគោតម ឯប្រស្នានេះនឹងយកមកតម្រូវលើរូបសេចក្ដីនេះមិនបានឡើយ ព្រោះថាភ្លើងដែលអាស្រ័យនឹងគ្រឿងបង្កាត់របស់ស្មៅនឹងឧស តែកាលណាឧសនឹងស្មៅនេះសុសអស់ហើយ នឹងមានភ្លើងថ្មីពីណាមកបាន ហើយដោយគ្មានគ្រឿងបង្កាត់ដូច្នេះ ក៏ភ្លើងនោះហៅថាភ្លើងរលត់ ។

- ម្នាលវច្ឆៈ រូបខន្ធ វេទនាខន្ធ សញ្ញាខន្ធ សង្ខារខន្ធ នឹងវិញ្ញាណក្ខន្ធដែលបោះបង់ចោលហើយដែលកាត់ឫសកែវចោលហើយដោយមិនមានជីវិតមិនមានជំនាញ ដែលអាចនឹងប្រាកដឡើងបានក្នុងអនាគតកាល ព្រះអរហន្តដែលលោករួចស្រឡះពីគំនុំណាតុទាំង ៥ នោះមានសភាពជ្រៅណាស់នឹងគណនាពុំបាន

មានគួរតាផ្លូវជាមមហាសមុទ្រថ្លោះឯង ក្នុងហេតុនេះនឹងពោល ថាព្រះអរហន្តនោះលោកចាប់កំណើតឡើងវិញជាថ្មីក៏មិនត្រូវថា លោកមិនយកកំណើតវិញក៏មិនត្រូវ ។

ថាលោកមិនយកកំណើតថ្មីទៀត ឬមិនមិនយកកំណើត ទៀត ក៏មិនត្រូវទ្បើយ ។

គេមិនអាចនឹងនិយាយបានថា ព្រះអរហន្តយកកំណើត ទៀតទ្បើយ ដោយអំណាចលោកបានកំចាត់នូវសេចក្ដីប្រាថ្នា នឹងរស ឬសេចក្ដីបំណងនឹងរស់ជាដ្រះស្រទ្បះហើយ ហើយមិន អាចនឹងពោលបានទ្បើយថា ព្រះអរហន្តលោកបំផ្លាញទំលាយ ខន្ធបានផង ព្រោះលោកគ្មានអ្វីនឹងបំផ្លាញទំលាយទ្បើយ ។

តាមន័យយ៉ាងជិតាញរបស់ធម៌នោះឃើញថា ព្រះពុទ្ធសា- សនាមិនប្រកែកដាច់ស្មោះថា គ្មានអត្តភាពនោះទ្បើយ គឺគ្រាន់ តែពន្យល់ថាមិនមែនជាវត្ថុដែលនៅទៀងជាដាច់ខាតនោះទេ ។ ពាក្យរបស់ព្រះពុទ្ធសាសនាដែលហៅទៅលើលក្ខណៈ របស់ បុគ្គលគឺ (សន្តាន) គឺជាវលក ១ ឬទន្លេ ១ ពាក្យដែលហៅនេះ ដោយទាំងជាតុវិញ្ញាណនឹងជាតុរូបទៅផងមានកម្លាំងម្យ៉ាងផ្សេង

ហៅថា កម្មសម្រាប់បង់នូវធាតុទាំងឡាយឲ្យដាច់ជាមួយគ្នា រលកនៃធាតុដែលផ្គុំជាមួយគ្នា មិនកំណត់ត្រឹមជាតិជាបច្ចុប្បន្ននេះ ប៉ុន្តែមានឫសកែវនៅក្នុងជាតិមុនៗ ដែលកន្លងទៅហើយ ហើយដាប់តៗ មកក្នុងអនាគត នេះជាបំណែកវិធីខាងព្រះពុទ្ធសាសនាដែលជំទាស់ផ្ទុយគ្នា នឹងព្រលឹង ឬឥន្ទ្រិយ របស់វិធីសាសនាផ្សេងៗ នឹងវិធីបរមត្ថផ្សេងៗឯទៀតឃើញថាតាមលំអានព្រះពុទ្ធសាសនានោះ មានខ្សែធម្មតា១ ឬកម្លាំងធម្មតា១ បើដូច្នេះគេអាចនឹងវិនិច្ឆ័យសេចក្ដីដោយម៉ត់ចត់ថា ព្រះនិព្វាននោះជាសេចក្ដីឈប់នៃខ្សែនេះដោយដាច់ខាត ប៉ុន្តែសភាពនៃបរមសុខដែលនៅជាខាងឆាយនោះ នឹងមានពាក្យណាមួយពោលឲ្យបំក៏ឥតអង្គមាន ៕៚—

(សំនៅងមកតាមសេចក្ដីអធិប្បាយរបស់ភិក្ខុនារទ ចប់តែត្រឹមនេះ)